00283793

C22/5/17

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 02 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ary

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:០០២/១២-០៩-២០០៧-អវតក-កសចស(អបជ១៧)

## <u>របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង</u>

I- **នីតិវិធី**

II- **ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍**

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ary

---

### I. នីតិវិធី

### ក) សេចក្តីផ្តើម

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងចៅក្រម **ន័យ ថុល** និងចៅក្រម Katinka Lahuis ឱ្យធ្វើរបាយការណ៍បង្ហាញលម្អិតពីអង្គហេតុ និងអង្គច្បាប់ ទាក់ទងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចេញដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨[1] ដែលដីកាសម្រេចនេះ ត្រូវបានប្តឹងឧទ្ធរណ៍ និងបង្ហាញអង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៧)។

### <u>អត្តសញ្ញាណសម្គាល់ជនត្រូវចោទ</u>

**អៀង សារី** ហៅ **វ៉ាន់** ភេទប្រុស កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿង វ៉ា ឃុំលឿង វ៉ា ស្រុកត្រា វិញ ខេត្តត្រាវិញ កម្ពុជាក្រោម សញ្ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួននៅផ្ទះលេខ

---

[1] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ("ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន") ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ C22/4។

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00283794

C22/5/17



៤៧បេ ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ឪពុកឈ្មោះ **គីម រៀម** (ស្លាប់) ម្តាយឈ្មោះ **ត្រាន់ ធិឡើយ** (ស្លាប់)[2]។

**អៀង សារី** មានសហមេធាវីការពារក្តីគឺលោក **អាង ឧត្តម** និង លោក Michael KARNAVAS[3]។

## បទចោទប្រកាន់

**អៀង សារី** ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤[4]។

## គោលបំណងរបស់របាយការណ៍

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ បង្ហាញលម្អិតពីអង្គហេតុ និងអង្គច្បាប់ទាក់ទងនឹងសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ និងអង្គហេតុដែលពាក់ព័ន្ធផ្សេងៗទៀត នៅចំពោះមុខតុលាការ។ របាយការណ៍នេះ ផ្តល់ជាជំនួយដល់អ្នកដែលមិនមែនជាភាគីនៃនីតិវិធីឲ្យបានយល់ដឹងអំពីរឿងក្តីនេះ នៅចំពោះមុខតុលាការ។

---

[2] ដីកាសម្រេចឃុំខ្លួន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C23 ទំព័រទី១

[3] លិខិតរបស់អង្គភាពគាំពារការពារក្តីដែលចាត់តាំងលោក **អាង ឧត្តម** ជាមេធាវីតំណាងឲ្យ **អៀង សារី** ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧; លិខិតរបស់អង្គភាពគាំពារការពារក្តីដែលចាត់តាំងលោក **អាង ឧត្តម** ជាមេធាវីតំណាងឲ្យ **អៀង សារី** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៨; យោង: លោក **អៀង សារី៖** លិខិតរបស់អង្គភាពគាំពារការពារក្តីដែលចាត់តាំងសហមេធាវីជាអចិន្ត្រៃយ៍ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨ និងសេចក្តីសម្រេចទទួលស្គាល់សហមេធាវី ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨។

[4] ដីកាសម្រេចឃុំខ្លួន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C23 ទំព័រទី១

00283795

C22/5/17

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៧)

## ខ) ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតរបស់អ.វ.ត.ក បានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំ[5]។

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា លក្ខខណ្ឌទីមួយដើម្បីចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងវិធាន៦៣(៣)(ក) ត្រូវបានបំពេញ ដោយសារតែមានហេតុផលដែលនាំឱ្យជឿជាក់ច្បាស់ថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានគេចោទប្រកាន់"[6]។ ក្នុងការចេញដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបានផ្អែកទាំងស្រុងលើការវិភាគសំណុំរឿងដែលបានសម្រេចដោយអង្គបុរេជំនុំជម្រះ នៅពេលទទួលបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដំបូង ដែលសេចក្តីសម្រេចនេះមិនទាន់មានភស្តុតាងណាមួយផ្សេងមកដោះបន្ទុកនៅឡើយទេ។

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា មិនមានការផ្លាស់ប្តូរស្ថានភាព ចាប់តាំងពីអង្គបុរេជំនុំជម្រះបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បីធានានូវអំពីវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលដំណើរការនីតិវិធី ការពារសន្តិសុខឱ្យជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា មូលហេតុទាំងបី ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៦៣(៣)(ខ) នៅតែត្រូវបានបំពេញ[7]។

---

[5] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន

[6] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ១១

[7] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ២០ ដល់ ៣១

សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់បន្ថែមថា "ខ្លួនមិនមើលឃើញមានលក្ខខណ្ឌ*សមហេតុផល* ណាមួយដែលភ្ជាប់ជាមួយនឹងការឃុំខ្លួននៅក្នុងផ្ទះ អាចធានាបាននូវលក្ខខណ្ឌកំណត់នៅក្នុងវាក្យខ័ណ្ឌ៣ ដល់វាក្យខ័ណ្ឌ៥ នៃវិធាន៦៣(៣)(ខ) ដូចវិធានការឃុំខ្លួនបណ្តោះអាសន្នទេ"[8]។

សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនអស់រយៈពេលប្រមាណជិត១២ខែ មិនមាន"លក្ខណៈហួសហេតុទេ បើគិតពីទំហំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត"[9]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមទៀតថា ការអនុវត្តន៍សិទ្ធិនៅស្ងៀមរបស់ជនត្រូវចោទ "មិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ"[10] ទោះបីជាសិទ្ធិនេះត្រូវបានទទួលស្គាល់ និងមិនអាចជំទាស់បានក៏ដោយ។

## គ) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២00៨ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[11] ដែលបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះ ទុកជាមោឃៈនូវដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបង្គាប់ឲ្យដោះលែងជនត្រូវចោទជាបណ្តោះអាសន្ន ឬបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេត កែតម្រូវលក្ខខណ្ឌនៃការឃុំខ្លួន និងអនុញ្ញាតឲ្យមានលក្ខខណ្ឌឃុំខ្លួននៅក្នុងផ្ទះ[12]។ សហមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តកិច្ចស៊ើបអង្កេតដោយយកចិត្តទុកដាក់ និងមិនបានគោរពសិទ្ធិជាសារវ័ន្តរបស់ជនត្រូវចោទ[13]។

---

[8] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ៣៥ ដល់ ៣៦

[9] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ៣៨

[10] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ៤១

[11] បណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន "បណ្តឹងឧទ្ធរណ៍" ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២00៨, C22/5/1។

[12] បណ្តឹងឧទ្ធរណ៍ ទំព័រទី១៩

[13] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១

00283797

C22/5/17



## ឃ) សេចក្តីសន្និដ្ឋានរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីសន្និដ្ឋានរួម[14] តបទៅនឹងបណ្តឹងឧទ្ធរណ៍ ដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយសារតែ "ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត គឺសមហេតុផល មានយុត្តិកម្ម និងការប្រើប្រាស់ឆន្ទានុសិទ្ធិបានយ៉ាងត្រឹមត្រូវ"[15]។

## ង) ចម្លើយតបរបស់សហព្រះរាជអាជ្ញា

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ សហព្រះអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន[16] ស្នើសុំដល់អង្គបុរេជំនុំជម្រះ ឱ្យធ្វើការបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានថា ជនត្រូវចោទ "ខកខានមិនបានបង្ហាញឱ្យឃើញអំពីការផ្លាស់ប្តូរជាក់ស្តែងណាមួយអំពីកាលៈទេសៈនោះទេ ចាប់តាំងពីរូបគាត់ត្រូវបានសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនពីដំបូងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧មក"[17]។

---

[14] សេចក្តីសន្និដ្ឋានតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ("សេចក្តីសន្និដ្ឋានតបរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨, C22/5/6។

[15] សេចក្តីសន្និដ្ឋានតបរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៥។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា"), C22/5/7។

[17] ចម្លើយតបរបស់សហព្រះអាជ្ញា កថាខណ្ឌ២



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

C22/5/17



## II. ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

### ក) ការយកចិត្តទុកដាក់ក្នុងការអនុវត្តន៍កិច្ចស៊ើបអង្កេត

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា កិច្ចស៊ើបអង្កេតមិនបានអនុវត្តដោយយកចិត្តទុកដាក់នោះទេ ដោយសារតែ"មានភស្តុតាងបន្តិចបន្តួចតែប៉ុណ្ណោះ បានដាក់នៅក្នុងសំណុំរឿងទាក់ទងនឹងលោក **អៀង សារី** ឬជនត្រូវចោទផ្សេងទៀត"[18]។ កង្វះខាតនៃការយកចិត្តទុកដាក់នេះ នាំឲ្យ "រំលោភកាតព្វកិច្ចក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្របមួយ"[19] និងជនត្រូវចោទមិនអាចត្រូវដកហូតសិទ្ធិនេះ ដោយសារតែហេតុផលថា គាត់អនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់ខ្លួន[20]។ អាយុ និងសុខភាពមិនល្អរបស់ជនត្រូវចោទ គួរតែយកមកពិចារណាផងដែរ[21]។

សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណី បានសន្និដ្ឋានថា ការកើនឡើងនៃភស្តុតាងនៅក្នុងសំណុំរឿង ចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បដិសេធការលើកឡើងអំពីភាពខ្វះខាតនៃការយកចិត្តទុកដាក់[22]។

នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ភាពខ្វះខាតនៃការយកចិត្តទុកដាក់ពីសំណាក់សហចៅក្រមស៊ើបអង្កេត "គឺគ្មានអ្វីពាក់ព័ន្ធគ្នាជាមួយនឹងការសម្រេចលើការដោះលែងបណ្តោះអាសន្ន អនុលោមតាមវិធាន៦៣(៣)(ក) និង៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងនោះទេ"[23]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបន្ថែមថា ការអនុវត្តន៍សិទ្ធិនៅស្ងៀមមិនឆ្លើយ មិនបានប្រើប្រាស់

---

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០

[19] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១២

[20] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១១

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១២

[22] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣៦; សេចក្តីសន្និដ្ឋានតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៩។

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣៨

ប្រឆាំងនឹងជនត្រូវចោទទេ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាបានបន្ថែមថា "ជនត្រូវចោទម្នាក់អាចនឹង-ប្រសើរជាងអ្នកដទៃទៀត-ជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងដោះបន្ទុក"[24]។

**ខ) ភារកិច្ចរកភស្តុតាង**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា "សហចៅក្រមស៊ើបអង្កេត មានភារកិច្ចរកភស្តុតាង ដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) និង៦៣(៣)(ខ) ត្រូវបានបំពេញ"[25] និងថា "យុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្សបានរកឃើញដូចគ្នាថា ហានិភ័យដែលនាំឲ្យមានការឃុំខ្លួនពីដំបូងបានកាត់បន្ថយ ខណៈ ដែលពេលវេលាចេះតែកន្លងផុតទៅ"[26]។

ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញអត្តសញ្ញាណនៃការផ្លាស់ប្តូរស្ថានភាព ដែលតម្រូវចាំបាច់សម្រាប់ធ្វើការពិចារណាឡើងវិញអំពីការឃុំខ្លួន ឬការផ្លាស់ប្តូរលក្ខខណ្ឌនៃការឃុំខ្លួនជនត្រូវចោទ[27]។

**គ) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តិបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (វិធានផ្ទៃក្នុង ៦៣(៣)(ក))**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានលើកឡើងថា "ការបង្ហាញភស្តុតាងច្បាស់លាស់ជាងនេះគឺជាការចាំបាច់ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន៦៣(៣)(ក) បន្ទាប់ពីលោក **អៀង សារី** ត្រូវបានឃុំខ្លួនអស់រយៈពេលមួយឆ្នាំកន្លងមក ក្នុងអំឡុងនៃការស៊ើបសួរ។ ដោយខកខានមិនបានកំណត់ភស្តុតាងថ្មីណាមួយទាក់ទងថាតើ លោក **អៀង សារី** អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនកំពុងត្រូវបាន

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៧

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០

[27] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៧

ចោទ ដើម្បីបំពេញបន្ថែមទៅលើភស្តុតាង ដែលបានកំណត់រួចហើយដោយអង្គបុរេជំនុំជម្រះនោះ សហចៅក្រមស៊ើបអង្កេត មិនបានបំពេញភារកិច្ចរកភស្តុតាងដាក់បន្ទុក ដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន៦៣(៣)(ក) ត្រូវបានបំពេញនោះទេ"[28]។

សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីនានា បានឆ្លើយតបថា ចាប់តាំងពីមានសេចក្តីសម្រេចឃុំខ្លួនដំបូងមក កិច្ចស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតមានការរីកចម្រើនទៅមុខ[29]។ ភស្តុតាងនៅក្នុងសំណុំរឿងដាក់បន្ទុកទៅលើជនត្រូវចោទ មានកាន់តែច្រើនឡើងទាំងចំនួន និងភាពធ្ងន់ធ្ងរនៅក្នុងប៉ុន្មានខែថ្មីៗនេះ[30]។ "សាក្សីនានាបាននិយាយអំពី [ជនត្រូវចោទ]មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗ ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ"[31] និង "មិនមានភស្តុតាងដោះបន្ទុកសំខាន់ៗ ត្រូវបានរកឃើញ ដើម្បីបដិសេធចោលនូវការកំណត់អំពី "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់""[32]។

**ឃ) ការពិចារណាអំពីមូលហេតុដែលធ្វើឲ្យការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ (វិធានផ្ទៃក្នុង ៦៣(៣)(ខ))**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានលើកឡើងថា ការឃុំខ្លួននៅក្នុងផ្ទះគឺជាទម្រង់នៃការឃុំខ្លួនដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង ហេតុដូចនេះការឃុំខ្លួននៅក្នុងផ្ទះត្រូវតែលើកយកមក

---

28 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២

29 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២០; ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៩ និង ២០

30 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៣

31 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៤

32 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៦

ពិចារណា[33]។ លក្ខខណ្ឌសមហេតុសមផលអាចភ្ជាប់ទៅនឹងការឃុំខ្លួនក្នុងផ្ទះ ដើម្បីការពារដល់គោលបំណងនៃវិធាន៦៣(៣)(ខ)[34]។

សហមេធាវីការពារក្តីលើកឡើងថា ហានិភ័យនៃការរត់គេចខ្លួនដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត គឺជាហានិភ័យដោយការសន្មតតែប៉ុណ្ណោះ[35] ដោយសារតែ "គ្មានភស្តុតាងណាដែលបញ្ជាក់ថា ជនត្រូវចោទរៀបចំអនុវត្តនូវសកម្មភាពរត់គេចខ្លួន ឬរំខានដល់ដំណើរការកិច្ចការតុលាការនោះដែរ"[36]។ លក្ខខណ្ឌសម្រាប់ការឃុំខ្លួនមានដូចជា៖ (១) ការបង្ខាំងខ្លួននៅក្នុងគេហដ្ឋានរបស់គាត់ (២) ការដកហូតយកលិខិតឆ្លងដែនរបស់គាត់ និង(៣) ការដាក់គាត់នៅក្នុងគេហដ្ឋានរបស់គាត់ ដោយមានការយាមកាមពីកងកម្លាំងប្រដាប់អាវុធ ដែលលក្ខខណ្ឌទាំងនេះនឹងធានាឲ្យមានវត្តមានរបស់ជនត្រូវចោទនៅក្នុងសវនាការ[37]។

សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានបង្ហាញថា "មិនមានហានិភ័យជាក់ស្តែងដែលគម្រាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់លោក **អៀង សារី** នោះទេ"[38]។ ការសន្មតជាមុនរបស់សហចៅក្រមស៊ើបអង្កេតដែលលើកឡើងថា ការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង គឺជាទម្រង់នៃការឃុំខ្លួនចាំបាច់នៅពេលណាដែលវាលេចឮជាសាធារណៈថា មានទំនាក់ទំនងដូចដែលបានចោទប្រកាន់រវាង **ឌុច** និងលោក **អៀង សារី** គឺផ្អែកទាំងស្រុងលើគោលការណ៍សច្ចធារណ៍និរទោស "ដោយសារតែទឡ្ហីករណ៍នេះហាក់ដូចពិតជាបង្ហាញច្បាស់ថា (ក) មានទំនាក់ទំនងបែបនេះពិតប្រាកដមែន និង(ខ) ពិរុទ្ធភាពដូចដែលបានរងការចោទប្រកាន់របស់ **ឌុច** រងការចោទប្រកាន់ដូចគ្នាទៅនឹងការទទួលរងពិរុទ្ធភាពស្មើគ្នាដូចលោក **អៀង សារី** មែន"[39]។

---

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៧

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣២

[35] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៧

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៨

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤០

[38] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤៧

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤១ និង៤២



PRE-TRIAL CHAMBER

ចំពោះគោលបំណងក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ (វិធាន៦៣(៣)(ខ)(៥)) សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានយោងលើរបាយការណ៍ដែលបង្ហាញថា "ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា គឺពិតជាមានស្ថេរភាព និងសន្តិភាពពិតប្រាកដមែន"[40]។ សហចៅក្រមស៊ើបអង្កេត មិនបានពិចារណាអំពីអ្វីដែលតុលាការទាំងមូល អាចធ្វើបានដើម្បីធានាថា ហានិភ័យនៃសណ្តាប់ធ្នាប់សាធារណៈមិនបានកើតឡើងទេ។ ហើយសហមេធាវីការពារក្តីបានស្នើសុំថា ប្រសិនបើផ្នែកផ្សព្វផ្សាយដ៏ទូលំទូលាយ និងទំនាក់ទំនងសាធារណៈរបស់ អ.វ.ត.ក ពន្យល់ឱ្យបានច្បាស់លាស់ថា ការឃុំខ្លួននៅក្នុងផ្ទះគឺជាទម្រង់នៃការឃុំខ្លួនមួយ ដូច្នេះការគម្រាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈនឹងមិនអាចកើតមានឡើងនោះទេ[41]។

សហព្រះរាជអាជ្ញាបានឆ្លើយតបថា គ្មានការបង្ហាញភស្តុតាងថ្មី ចាប់តាំងពីអង្គបុរេជំនុំជម្រះបានសម្រេចនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់[42]។ វិធានផ្ទៃក្នុងមិនបានចែងអំពីជម្រើសនៃទម្រង់ឃុំខ្លួនផ្សេងទៀតទេ ក្រៅតែពីការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ មានតែវិធាន៦៥(១) ចែងអំពីការដោះលែងឱ្យមានសេរីភាពតាមការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប៉ុន្តែជនត្រូវចោទមិនអាចដោះលែងឱ្យមានសេរីភាពតាមដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ប្រសិនបើលក្ខខណ្ឌណាមួយនៃវិធាន៦៣(៣)(ខ) ត្រូវបានបំពេញ[43]។

សហព្រះរាជអាជ្ញា សន្និដ្ឋានថា "ទោះបីជាចុងចោទត្រូវបានដាក់ឱ្យជាប់ឃុំក្នុងផ្ទះ ឬ "ឃុំខ្លួនក្នុងមន្ទីរពេទ្យ"ក៏ដោយ ក៏វាអាចមានហានិភ័យយ៉ាងខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ដែរ។ គាត់នឹងតម្រូវឱ្យមកកាន់បរិវេណអ.វ.ត.ក ទៅតាមកាលៈទេសៈខុសៗគ្នា ហើយវានឹងមានការលំបាកដើម្បីធានាចំពោះសុវត្ថិភាពរបស់គាត់ ក្នុងពេលដឹកជញ្ជូនចេញពីមន្ទីរពេទ្យ ឬពីផ្ទះរបស់គាត់ មកកាន់

---

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤៩

[41] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥០ និង៥១

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៩

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣១

C 22/5/17



អ.វ.ត.ក ដើម្បីចូលរួមផ្ទាល់នៅក្នុងសវនាការសាធារណៈផ្សេងៗ។ ម្យ៉ាងទៀត មន្ទីរឃុំឃាំង អ.វ.ត.ក "ត្រូវបានបំពាក់ឧបករណ៍យ៉ាងត្រឹមត្រូវ ដើម្បីផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ទៅតាមការចាំបាច់""[44]។

សហមេធាវីការពារក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបថា ឧប្បត្តិហេតុដែលកើតឡើងរវាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តីរបស់ **អៀង សារី** ក្នុងអំឡុងពេលសន្និសីទក្រោយសវនាការ បង្ហាញអំពី "ភាពតានតឹងនៅមានកម្រិតខ្ពស់ក្នុងសង្គមកម្ពុជា"[45] និងហានិភ័យសន្តិសុខរបស់ជនត្រូវចោទប្រសិនជាគាត់ត្រូវបានដោះលែង។

ភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨

**សហចៅក្រមរបាយការណ៍**

**ចៅក្រម នៃយ ថុល** | **ចៅក្រម** Katinka Lahuis

---

[44] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣២

[45] សេចក្តីសន្និដ្ឋានតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៥